

ក្រសួងអប់រំ យុវជន និងកីឡា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឯកសារជំនួយ
ការបង្រៀនភាសាអង់គ្លេស
ថ្នាក់ទី៦

ជាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា

២០១៩

អារម្ភកថា

ធនធានមនុស្សជាកម្លាំងចលករមួយចាំបាច់បំផុតក្នុងការអភិវឌ្ឍប្រទេសជាតិ។ គោលដៅសាលារៀនចំណេះទូទៅគឺ ការកសាងធនធានមនុស្សឱ្យក្លាយជាពលរដ្ឋពេញលេញ ដែលប្រកបដោយចំណេះដឹង ជំនាញ និងឥរិយាបថ។ ដើម្បីសម្រេចគោលដៅនេះ ក្រសួងអប់រំ យុវជន និងកីឡា បានអភិវឌ្ឍសៀវភៅសិក្សាគោលភាសាអង់គ្លេសជាបន្តបន្ទាប់ពីថ្នាក់ទី៤ឡើងទៅ ព្រមទាំងឯកសារណែនាំការបង្រៀនភាសាអង់គ្លេស ដើម្បីជាជំនួយដល់ការបង្រៀនឱ្យបានសមស្រប និងឯកភាពគ្នា។

គណៈកម្មការរៀបចំឯកសារណែនាំការបង្រៀនភាសាអង់គ្លេសនៃក្រសួងអប់រំ យុវជន និងកីឡា បានរៀបរៀងឯកសារនេះឡើងស្របទៅនឹងខ្លឹមសារនៃសៀវភៅសិក្សាគោលភាសាអង់គ្លេសថ្នាក់ទី៦ ដែលរួមមាន៦ជំពូក និង៣៦មេរៀន ដើម្បីជាជំនួយដល់លោកគ្រូ អ្នកគ្រូ ក្នុងការបង្រៀនភាសាអង់គ្លេសឱ្យស្របនឹងលទ្ធផលសិក្សា ខ្លឹមសារតាមកម្រិតមេរៀនដោយរួមមាន ពាក្យងាយៗ និងអត្ថបទខ្លីៗក្នុងបរិបទគ្រួសារ សាលារៀន និងសហគមន៍ ដែលជាតម្រូវការជាក់ស្តែងរបស់សិស្សានុសិស្សក្នុងបរិបទកម្ពុជា។

ឯកសារនេះ ត្រូវបានរៀបរៀងឡើងជាភាសាខ្មែរ និងមានឧទាហរណ៍មួយចំនួន ព្រមទាំងចម្លើយរបស់សំណួរនៅក្នុងមេរៀននីមួយៗ ក្នុងន័យផ្តល់ភាពងាយស្រួលសម្រាប់លោកគ្រូ អ្នកគ្រូក្នុងការបង្រៀន ជាពិសេស
លោកគ្រូ អ្នកគ្រូ ដែលមិនមែនឯកទេសភាសាអង់គ្លេស។

គណៈកម្មការរៀបចំឯកសារណែនាំការបង្រៀនភាសាអង់គ្លេសយើងខ្ញុំសង្ឃឹមថា លោកគ្រូ អ្នកគ្រូនឹងប្រើប្រាស់ឯកសារណែនាំនេះ ជាឯកសារជំនួយស្មារតីក្នុងការបង្រៀន ដើម្បីអភិវឌ្ឍចំណេះដឹង បំណិនទាំងបួនគឺ និយាយ អាន ស្តាប់ និងសរសេរដោយផ្តោតសំខាន់លើបំណិនទំនាក់ទំនងមូលដ្ឋានក្នុងការនិយាយភាសាអង់គ្លេស ដែលជាមូលដ្ឋានគ្រឹះក្នុងការពង្រឹងសមត្ថភាពរបស់សិស្សដើម្បីបន្តទៅថ្នាក់បន្ទាប់ៗទៀត។

គណៈកម្មការរៀបចំឯកសារណែនាំការបង្រៀនភាសាអង់គ្លេសយើងខ្ញុំ រីករាយរង់ចាំទទួលនូវមតិយោបល់ស្ថាបនាពីលោកគ្រូ អ្នកគ្រូ និងអ្នកមានចំណាប់អារម្មណ៍ទាំងអស់ ដើម្បីកែលម្អឯកសារនេះឱ្យកាន់តែប្រសើរឡើងថែមទៀត។

គណៈកម្មការរៀបចំ

គណៈកម្មការអភិវឌ្ឍឯកសារជំនួយការបង្រៀនភាសាអង់គ្លេសថ្នាក់ឆ្នាំ ៦

គណៈកម្មការគ្រប់គ្រង

ឯកឧត្តម បណ្ឌិតសភាចារ្យ **ហង់ ជួន ណារ៉ុន**

ឯកឧត្តម បណ្ឌិត **អ៊ឹម រុច**

លោកជំទាវ **ទន់ សារ៉ឹម**

គណៈកម្មការត្រួតពិនិត្យ

ឯកឧត្តម **ពុត សាមិត្ត**

ឯកឧត្តម **ឡោ ឆវណ្ណា**

គណៈកម្មការរៀបចំ

លោក **អាំ សុបុល**

លោក **ឡេង សារី**

លោកស្រី **កែវ រដ្ឋា**

លោក **ម៉ិញ សុភា**

លោក **ឆឹម ឋន**

លោកស្រី **ឆន ពេជ្រឆារី**

លោក **ជូ ឋណ្ណនា**

លោក **កើត សុភុមារ**

ជំនួយការបច្ចេកទេស

Mrs. **Vicky Dyer**

Mr. **Colin Holmes**

គណៈកម្មការចូលរួមកែលម្អ

លោក **តុង ឫទ្ធិ**

លោក **លី គាង**

លោក **ចិន សុភារ**

លោកស្រី **ផន សុភា**

លោក **គីម ផេង**

លោកស្រី **រិន ពុធចារី**

លោក **ឡូញ រិទ្ធ**

លោក **ជុំ ធិត**

លោកស្រី **ស្បឿន សុភក្តិនី**

កញ្ញា **រិន ចាន់ធី**

លោក **ឡូញ រិទ្ធ**

លោកស្រី **ប៉ែន តុលា**

លោក **ខ្លូត រឿន**

លោក **សេក ឡឿន**

លោក **អ៊ុយ តារក្ស**

លោក **ជឹន ថេន**

លោក **រ៉ូ តារុំ**

លោកស្រី **ប្រឹម សុផាណ្ណា**

លោក **ស្វាយ សេរីវុឌ្ឍា**

លោក **ឆេង សុខុម**

Mr. **Will Anda**

លោកស្រី **ចិន សុជាតិ**

លោក **ឆាង កុសល**

គណៈកម្មការអនុម័ត

លោកជំទាវ **ទន់ សារ៉ឹម**

លោក **យិន ធី**

លោក **ឈឹម សុត្ថារិទ្ធ**

មាតិកា

អារម្ភកថា i
គណៈកម្មការអភិវឌ្ឍឯកសារជំនួយការបង្រៀនភាសាអង់គ្លេសថ្នាក់ទី ៦ ii
មាតិកា..... iii
សេចក្តីណែនាំ v
Sample Lesson Plan for the First Hour គំរូកិច្ចតែងការបង្រៀនសម្រាប់ម៉ោងទី ១.....x
Sample Lesson Plan for the Second Hour គំរូកិច្ចតែងការបង្រៀនសម្រាប់ម៉ោងទី ២…….xii
Chapter 1: TIME AND ACTIVITIES ជំពូកទី១៖ ពេលវេលា និងសកម្មភាព 1
Unit 1: Greetings And Introduction មេរៀនទី១៖ កិច្ចស្វាគមន៍ និងការណែនាំខ្លួន 1
Unit 2: Telling The Time មេរៀនទី២៖ ការប្រាប់ពីពេលវេលា.....4
Unit 3: Feeling Happy មេរៀនទី៣៖ អារម្មណ៍សប្បាយរីករាយ.....7
Unit 4: Time At Home មេរៀនទី៤៖ ពេលវេលានៅផ្ទះ 9
Unit 5: Time At School មេរៀនទី៥៖ ពេលវេលានៅសាលារៀន 12
Unit 6: Review មេរៀនទី៦៖ រំឭកមេរៀនឡើងវិញ.....15
Chapter 2: THE DATE ជំពូកទី២៖ កាលបរិច្ឆេទ 17
Unit 1: The Days មេរៀនទី១៖ ថ្ងៃ 17
Unit 2: The Months មេរៀនទី២៖ ខែ 20
Unit 3: Family Birth Dates មេរៀនទី៣៖ កាលបរិច្ឆេទខួបកំណើតគ្រួសារ.....23
Unit 4: My Special Day 26
Unit 5: School Events មេរៀនទី៥៖ ពិធីផ្សេងៗនៅសាលារៀន 29
Unit 6: Review មេរៀនទី៦៖ រំឭកមេរៀនឡើងវិញ.....32
Chapter 3: MY BODY ជំពូកទី៣៖ រាងកាយរបស់ខ្ញុំ 35
Unit 1: My Head មេរៀនទី១៖ ក្បាលរបស់ខ្ញុំ.....35
Unit 2: My Arms And Legs មេរៀនទី២៖ ដៃ និងជើងរបស់ខ្ញុំ 38
Unit 3: Appearance មេរៀនទី៣៖ រូបរាងកាយខាងក្រៅ.....40
Unit 4: Body Functions មេរៀនទី៤៖ មុខងារនៃរាងកាយ 43
Unit 5: Body Care មេរៀនទី៥៖ ការថែទាំរាងកាយ.....46
Unit 6: Review មេរៀនទី៦៖ រំឭកមេរៀនឡើងវិញ.....49
Chapter 4: MY HOMETOWN ជំពូកទី៤៖ ស្រុកកំណើតរបស់ខ្ញុំ.....52
Unit 1: Where Do You Live? មេរៀនទី១៖ តើអ្នករស់នៅឯណា?.....52
Unit 2: The Way To My House មេរៀនទី២៖ ផ្លូវទៅផ្ទះរបស់ខ្ញុំ.....54

Unit 3: A Market In My Village មេរៀនទី៣៖ ផ្សារនៅភូមិខ្ញុំ 57
Unit 4: Favourite Places មេរៀនទី៤៖ ទីកន្លែងដែលខ្ញុំចូលចិត្ត 60
Unit 5: The Village Products មេរៀនទី៥៖ ផលិតផលក្នុងភូមិ 63
Unit 6: Review មេរៀនទី៦៖ រំឭកមេរៀន 66
Chapter 5: ANIMALS ជំពូកទី៥៖ សត្វ 7069
Unit 1: Pets មេរៀនទី១៖ សត្វចិញ្ចឹម 7069
Unit 2: Wild Animals មេរៀនទី២៖ សត្វព្រៃ..... 7372
Unit 3: Sea Creatures មេរៀនទី៣៖ សត្វសមុទ្រ 7675
Unit 4: Farm Animals មេរៀនទី៤៖ សត្វស្រុក 7978
Unit 5: Dangerous Animals មេរៀនទី៥៖ សត្វដែលនាំឱ្យគ្រោះថ្នាក់..... 8281
Unit 6: Review មេរៀនទី៦៖ រំឭកមេរៀនឡើងវិញ..... 8584
Chapter 6: KHMER FOLK TALES ជំពូកទី៦៖ រឿងនិទានខ្មែរ 8786
Unit 1: The Hen And The Chicks មេរៀនទី១៖ មេមាន់ និងកូនមាន់ 8786
Unit 2: The Bear And The Bees មេរៀនទី២៖ ខ្លាឃ្មុំ និងឃ្មុំ..... 9089
Unit 3: The Elephant And The Hare មេរៀនទី៣៖ ដំរី និងទន្សាយព្រៃ 9392
Unit 4: The Tiger, Cat And Rats មេរៀនទី៤៖ ខ្លា ឆ្មា និង កណ្តុរ 9594
Unit 5: The Blackbirds And The Monkey មេរៀនទី៥៖ សត្វសារិកា និងស្វា..... 9897
Unit 6: Review មេរៀនទី៦៖ រំឭកមេរៀនឡើងវិញ..... 101100

សេចក្តីណែនាំ

១. ការបង្រៀនភាសាអង់គ្លេស

ក្រសួងអប់រំ យុវជន និងកីឡា បានដាក់បញ្ចូលមុខវិជ្ជាភាសាអង់គ្លេសក្នុងកម្មវិធីសិក្សានៅកម្រិតបឋមសិក្សា ចំណេះទូទៅពីថ្នាក់ទី៤ដល់ថ្នាក់ទី៦ ដើម្បីផ្តល់ឱកាសឱ្យសិស្សបានសិក្សាជាមូលដ្ឋានដំបូងនៃភាសាអង់គ្លេស សម្រាប់ជាគ្រឹះក្នុងការបន្តការសិក្សានៅកម្រិតមធ្យមសិក្សា។ ដូច្នេះ សាលារៀននីមួយៗត្រូវអនុវត្តកម្មវិធីសិក្សា និងសៀវភៅសិក្សាគោលភាសាអង់គ្លេសឱ្យមានប្រសិទ្ធភាពដូចខាងក្រោម៖

១.១ ការប្រើប្រាស់សៀវភៅភាសាអង់គ្លេស

គ្រប់គ្រឹះស្ថានសិក្សាបឋមសិក្សាចំណេះទូទៅសាធារណៈទាំងអស់ត្រូវប្រើប្រាស់សៀវភៅ English Grade 4 to 6 ជាសៀវភៅសិក្សាគោលរបស់ក្រសួងអប់រំ យុវជន និងកីឡា សម្រាប់ការបង្រៀន និងរៀននៅតាមសាលាបឋមសិក្សាទូទាំងប្រទេស។

១.២ ការប្រើប្រាស់ម៉ោងសិក្សា

១.២.១ ការបង្រៀន និងរៀនភាសាអង់គ្លេស ត្រូវបែងចែករបាយម៉ោងឱ្យបានច្បាស់លាស់ក្នុងកាលវិភាគប្រចាំ

សប្តាហ៍ដោយអនុវត្តទៅតាមការកំណត់ក្នុងក្របខណ្ឌកម្មវិធីសិក្សា ០២ម៉ោងសិក្សាក្នុងមួយសប្តាហ៍ ត្រូវនឹង ៣៥សប្តាហ៍ក្នុងមួយឆ្នាំ ហើយ០១ម៉ោងសិក្សាមានរយៈពេល៤០នាទី ដូច្នេះ៖

- សរុបម៉ោងកំណត់ : ២ម៉ោង x ៣៥សប្តាហ៍ = ៧០ ម៉ោងសិក្សាក្នុងមួយឆ្នាំ
- សរុបម៉ោងបង្រៀន: ២ម៉ោង x ៣៣សប្តាហ៍ = ៦៦ ម៉ោងសិក្សាក្នុងមួយឆ្នាំ
- សរុបម៉ោងសល់ : ២ម៉ោង x ២សប្តាហ៍ = ០៤ ម៉ោងសិក្សាក្នុងមួយឆ្នាំ ម៉ោងដែលនៅសល់ គ្រូអាចរំឭកមេរៀនសារឡើងវិញ ឬធ្វើលំហាត់បន្ថែម។

១.២.២ ប្រធានកម្រងត្រូវសហការជាមួយនាយកសាលារៀបរៀបចំកាលវិភាគឱ្យបានច្បាស់លាស់គ្រប់សាលាបឋមសិក្សាដើម្បីអនុវត្តការបង្រៀន និងរៀនភាសាអង់គ្លេសបានឯកភាពគ្នា។

១.៣ ការប្រើប្រាស់ធនធានគ្រូបង្រៀន

១.៣.១ នាយកសាលារៀនចាត់តាំងគ្រូបង្រៀនដែលមានចំណេះដឹងផ្នែកភាសាអង់គ្លេស ឬធ្លាប់បានចូលរួមក្នុងវគ្គតម្រង់ទិសការប្រើប្រាស់កម្មវិធីសិក្សា សៀវភៅសិក្សាគោល និងវិធីសាស្ត្របង្រៀនភាសាអង់គ្លេសពីថ្នាក់ទី៤ដល់ថ្នាក់ទី៦ដល់គ្រូបង្គោលសម្រាប់បង្រៀនទាំងបីកម្រិតថ្នាក់។ ចំពោះម៉ោងដែលគ្រូបង្រៀននោះនៅសេសសល់ ត្រូវជួយការងាររដ្ឋបាល ឬបណ្ណាល័យសាលារៀន។

១.៣.២ សាលារៀនដែលពុំទាន់ឆ្លងកាត់វគ្គតម្រង់ទិសការប្រើប្រាស់កម្មវិធីសិក្សានិងសៀវភៅសិក្សាគោល និងវិធីសាស្ត្របង្រៀនភាសាអង់គ្លេសពីថ្នាក់ទី៤ដល់ថ្នាក់ទី៦ គណៈគ្រប់គ្រងសាលារៀន ត្រូវជ្រើសរើសយកគ្រូបង្រៀនដែលចេះភាសាអង់គ្លេសសម្រាប់បង្រៀនមុខវិជ្ជាភាសាអង់គ្លេសពីថ្នាក់ទី៤ដល់ទី៦ ហើយសមាសភាពគ្រូទាំងនោះជាមុខសញ្ញាក្នុងការទទួលការបណ្តុះបណ្តាលជំនាញ ឬបំប៉នសមត្ថភាពផ្នែកកម្មវិធីសិក្សា សៀវភៅសិក្សាគោល និងវិធីសាស្ត្របង្រៀនភាសាអង់គ្លេសនៅពេលអនាគត។

១.៤ ការកំណត់ពិន្ទុ

ការដាក់ពិន្ទុ ត្រូវធ្វើការវាយតម្លៃទៅលើសមាសភាគទាំងបួននៃភាសាអង់គ្លេសគឺ ការស្តាប់ ការនិយាយ ការអាន និងការសរសេរ ដែលពិន្ទុសរុបស្មើនឹង ១០ពិន្ទុ ដូចមុខវិជ្ជាដទៃទៀតដែរ។

២. វិធីសាស្ត្របង្រៀន

ការបង្រៀនតួអក្សរ គ្រូបង្រៀនត្រូវបញ្ជាក់ពីបន្ទាត់និងខ្សែកោង និងបង្រៀនគូសតួអក្សរនាំមុខជាមុនសិន ដោយសង្កត់ធ្ងន់ពីបន្ទាត់ឡើង ចុះ មូល កាត់ ចុច ដើម្បីសម្រួលចលនាដៃរបស់កុមារ ចៀសវាងការច្រឡំក្នុងការគូសមិនបានត្រឹមត្រូវ ឆ្វេង ស្តាំ លើ ក្រោម មុខ ក្រោយ ជាដើម។ ការបង្រៀនគូសអក្សរព្យញ្ជនៈ គ្រូគប្បីណែនាំសិស្សឱ្យបានច្បាស់លាស់ពីរបៀបគូស ឬសរសេរនូវចំណុចចាប់ផ្តើម និងបញ្ចប់ ចៀសវាងសិស្សសរសេរបញ្ច្រាស។

បន្ទាប់ពីសិស្សគូស ឬសរសេរតួអក្សរបានស្ទាត់ជំនាញ គ្រូអាចបង្រៀនសិស្សអាន និងសរសេរតួអក្សរ និងពាក្យបានត្រឹមត្រូវ។ បន្ទាប់មក គ្រូប្រើចំណេះដឹងបន្តបង្រៀនពីឃ្លា ប្រយោគបែបសំណួរចម្លើយ និងសន្ទនា លើសពីនេះគ្រូក៏អាចបន្តទៅដល់ការអានអត្ថបទខ្លីៗ ដើម្បីឱ្យសិស្សមានជំនាញស្តាប់ និងនិយាយបានស្ទាត់។ គ្រូគប្បីចៀសវាងការបង្រៀនឱ្យសិស្សចេះចាំស្ទាត់មាត់ តែពុំចេះតួអក្សរ និងពាក្យបានច្បាស់លាស់ ជាហេតុធ្វើឱ្យពិបាកដល់ការបង្រៀនអំពីឃ្លា ប្រយោគ និងអត្ថបទ ដែលអាចធ្វើឱ្យសិស្សធុញថប់ក្នុងការសិក្សា ឬសិក្សាមិនប្រកបដោយប្រសិទ្ធភាព។ ដូច្នេះ ការបង្រៀនដែលទទួលបានជោគជ័យ និងមានមូលដ្ឋានរឹងមាំ គ្រូគប្បីយកចិត្តទុកដាក់ជួយសិស្សឱ្យចេះអាន ចេះសរសេរបានត្រឹមត្រូវ គួបផ្សំនឹងការប្រើប្រាស់សម្ភារៈក្នុងការបង្រៀនពាក្យ ឬឃ្លាប្រយោគ និងប្រើវិធីលេងល្បែងសិក្សាដែលជាល្បែងមួយនាំឱ្យគ្រូសម្រេចការបង្រៀនឆ្លើយតបនឹងវត្ថុបំណងមេរៀន ជួយសិស្សឱ្យរៀនឆាប់យល់តាមរយៈការធ្វើសកម្មភាព ឬអាចនិយាយបានថា រៀនផង អនុវត្តផង និងលេងផង និងនាំឱ្យគ្រូទទួលបាននូវប្រសិទ្ធភាព អាចធ្វើឱ្យសិស្សឆាប់ចាប់បាននូវខ្លឹមសារមេរៀន ជាពិសេសអាចផ្តល់ឱ្យសិស្សរៀនចេះច្រើន និងមានភាពសប្បាយរីករាយដោយលេងល្បែងរួមនឹងការសិក្សា លើសនេះទៀត អាចជំរុញការពិចារណាហ្មត់ចត់ មានគំនិតច្នៃប្រឌិត ព្រមទាំងបណ្តុះគំនិតសហការ និងពង្រឹងស្មារតីសិស្សឱ្យក្លាហាន ឈានទៅរកដំណោះស្រាយបញ្ហា ការសម្រេចចិត្ត ឬបង្កើតយោបល់។

កម្មវិធីសាលាកុមារមេត្រី ទាមទារឱ្យគ្រូចេះលើកទឹកចិត្តសិស្សដោយការសរសើរ ឬផ្តល់រង្វាន់ មិនត្រូវធ្វើឥរិយាបថណាដែលនាំឱ្យសិស្សខ្លាចមិនហ៊ានចូលរួម មិនហ៊ាននិយាយ ត្រូវជួយសិស្សឱ្យមានសង្ឃឹម ហ៊ានសួរ ហ៊ានឆ្លើយ និងបង្កឱ្យមានបរិយាកាសសប្បាយរីករាយជាប្រចាំ។

៣. ការប្រើប្រាស់សម្ភារៈឧបទេស

គ្រូត្រូវការប្រើប្រាស់សម្ភារៈឧបទេសក្នុងការរៀននិងបង្រៀនតាមខ្លឹមសាររបស់មេរៀន។ ការប្រើសម្ភារៈឧបទេសមានប្រយោជន៍ក្នុងការទាក់ទាញទឹកចិត្តសិស្សឱ្យចូលចិត្តរៀន ចងចាំតាមរយៈការលើកបង្ហាញ និងចង្អុលបណ្តាតួអក្សរ បណ្តាពាក្យ ផ្ទាំងរូបភាព និងប្រដាប់បំពងសំឡេងដែលអាចជួយសិស្សអានពាក្យបានត្រឹមត្រូវ ធ្វើឱ្យសិស្សបានសប្បាយផង និងយល់ខ្លឹមសារមេរៀនបានច្បាស់ផង។

ពេលបង្រៀន គ្រូត្រូវការសម្ភារៈចាំបាច់បំផុតសម្រាប់អាន និងសរសេរនោះគឺ បណ្តាតួអក្សរ ឬតារាង ព្យញ្ជនៈ ២៦តួ បណ្តាពាក្យ ផ្ទាំងរូបភាព រូបភាព ប្រដាប់បំពងសំឡេង វត្ថុជាក់ស្តែង និងដីស ឬហ្វឺត តម្រូវទៅតាមខ្លឹមសារដែលត្រូវបង្រៀន។

សម្ភារៈឧបទេសងាយៗដែលគ្រូផលិតបាន មិនចំណាយថវិកា ហើយទុកប្រើប្រាស់បានយូរ ដោយគ្រាន់តែយកក្រដាសកាតុង ឬក្រដាសទ្បាំងដែលមានទំហំសមល្មម និងអាចសរសេរតួអក្សរ ឬពាក្យបាន។ ម៉្យាងទៀត ដើម្បីងាយស្រួលក្នុងការប្រើប្រាស់សម្ភារៈ គ្រូគួរចេះកែច្នៃសម្ភារៈដូចជា យកក្រដាសទ្បាំងស្រោបថង់ប្លាស្ទិចសម្រាប់សរសេរពាក្យជាមួយហ្វឺត អាចលុបចេញបាន និងប្រើបានរហូតគ្រប់មេរៀន។

៤. ការវាយតម្លៃ

ការបញ្ចប់មេរៀន គ្រូចាំបាច់ធ្វើការវាស់ស្ទង់លទ្ធផលសិក្សារបស់សិស្ស គប្បីធ្វើតាមមេរៀននីមួយៗ ពោលគឺធ្វើតេស្តតាមដំណាក់កាល ឬតេស្តក្នុងពេលបង្រៀន។ ចំណែកឯការធ្វើតេស្តបញ្ចប់គឺធ្វើឡើងនៅពេលចប់ជំពូក គឺប្រឡងប្រចាំខែ ឬប្រចាំឆមាស។

ការវាយតម្លៃត្រូវធ្វើឱ្យសមស្របទៅតាមខ្លឹមសារ និងវត្ថុបំណងមេរៀន និងជំពូកមេរៀន ដោយផ្អែកលើបំណិនចាំបាច់ទាំង៤ (ស្តាប់ និយាយ អាន និងសរសេរ)។ លោកគ្រូ អ្នកគ្រូត្រូវមានសមត្ថភាពរៀបចំកសាង Item Test ដូចជាដោយផ្តោតលើពាក្យ ឃ្លា ប្រយោគ អត្ថបទ បំពេញឃ្លា ប្រយោគ បំពេញពាក្យឱ្យត្រូវនឹងរូបភាព បំពេញចម្លើយផ្ទួរផ្តង និងឈានទៅរកការសរសេរតាមអាននូវពាក្យ និងកន្សោមពាក្យ ងាយៗ ព្រមទាំងសរសេរចំណងជើងរូបភាព។ល។

៥. លំនាំបង្រៀន

៥.១. ការបង្រៀនអាន និងប្រកបពាក្យ៖

- គ្រូណែនាំសិស្សឱ្យស្តាប់ (listen) និង មើល (look)
- គ្រូគួរប្រើរូបភាព បណ្តាពាក្យ ឬសរសេរពាក្យនៅក្បែររូបភាពនោះ។ ពេលដែលគ្រូសរសេរពាក្យនីមួយៗ ចូរនិយាយសូរអក្សរនីមួយៗ បន្ទាប់មកនិយាយពាក្យទាំងមូល។
- គ្រូធ្វើលំនាំដូចពាក្យនេះដែរចំពោះពាក្យថ្មីផ្សេងទៀត។

៥.២. គ្រូអានពាក្យ ឃ្លា ប្រយោគឱ្យច្បាស់ៗចំនួនបីដង (TechniqueT$_3$Cl) មុននឹងឱ្យសិស្សសរសេរលើក្តារឆ្នួន៖

- គ្រូអានពាក្យ ឬឃ្លាខ្លីៗបីដង ហើយឱ្យសិស្សម្នាក់ថាតាមមុននឹងសិស្សទាំងអស់សរសេរនៅលើក្តារឆ្នួន ឬសៀវភៅសរសេរ បន្ទាប់មកគ្រូអានឃ្លា ប្រយោគម្តងទៀតដើម្បីផ្ទៀងផ្ទាត់កិច្ចការឡើងវិញ
- គ្រូបំបែកឃ្លា ប្រយោគដែលវែងជាផ្នែកៗ ដើម្បីងាយឱ្យសិស្សស្តាប់ និងសរសេរតាម
- គ្រូអាចត្រួតពិនិត្យកិច្ចការសិស្ស ឬប្រមូលកិច្ចការសិស្សមកកែជាក់ពិន្ទុ ឬសិស្សអាចប្តូរកិច្ចការគ្នាដើម្បីរកមើលកំហុសឆ្គង និងកែលម្អ។

៥.៣. ការបង្រៀនអានអត្ថបទ និងសរសេរពាក្យ៖

- គ្រូ ឬសិស្សអាចអនុវត្តតាមរបៀបដូចខាងលើ(៥.២)បានចំពោះតួអក្សរ ឬពាក្យបន្តបន្ទាប់
- គ្រូបង្ហាញរូបភាព សរសេរពាក្យក្បែររូបភាព
- គ្រូអានពាក្យឱ្យសិស្សស្តាប់ជាក្រុម រួចឱ្យសិស្សអានម្នាក់ ឬបីនាក់អានតាម
- គ្រូអានពាក្យឱ្យសិស្សស្តាប់ជាមុន រួចឱ្យសិស្សអានជាក្រុម បន្ទាប់មកឱ្យសិស្សអានម្នាក់ ឬបីនាក់
- គ្រូអានជាគំរូនូវពាក្យ រួចឱ្យសិស្សអានពាក្យនោះម្នាក់ ឬបីនាក់
- គ្រូឱ្យសិស្សអានតាមក្រុម តាមជួរ ឬទាំងអស់គ្នា។

៥.៤. ការបង្រៀនអត្ថន័យនៃពាក្យ និងសរសេរឃ្លា ប្រយោគ៖

៥.៤.១. ការបង្រៀនអត្ថន័យនៃពាក្យ

- បង្ហាញរបស់ពិតជាក់ស្តែង ឬរូបភាព ឬក៏គូសរូបភាពបង្ហាញសិស្ស ហើយសរសេរពាក្យនៅក្បែរវត្ថុ ឬរូបភាព ក្នុងករណីដែលពាក្យនេះយើងងាយរកវត្ថុជាក់ស្តែង ឬសម្ភារៈ និងរូបភាព

- ក្នុងករណីដែលពាក្យងាយស្រួលក្នុងការពន្យល់ និងធ្វើកាយវិការ ដើម្បីឱ្យសិស្សទាញយកអត្ថន័យនៃពាក្យ យើងគួរពន្យល់អមដោយកាយវិការ
- ក្នុងករណីដែលពាក្យនោះមានការពិបាកនិងធ្វើកាយវិការពន្យល់ នោះយើងអាចបកប្រែតែម្តង។

៥.៤.២. ការបង្រៀនសរសេរឃ្លា ប្រយោគ

- គ្រូណែនាំសិស្សអំពីថ្នាក់របស់ពាក្យ ដែលនឹងយកមកបង្កើតជាឃ្លា ឬប្រយោគ
- គ្រូប្រាប់ធាតុផ្សំនៃប្រយោគ ប្រធាន កិរិយា និងកម្មបទ (Subject + verb + object)
- អនុវត្តក្នុងការសរសេរប្រយោគ៖ e.g. I go to school.
- ឱ្យសិស្សបង្កើតឃ្លា ប្រយោគជាមួយដៃគូ ឬក្រុម។

៥.៥. ការបង្រៀនសរសេរតាមអាន

- គ្រូអានពាក្យ ឃ្លា ប្រយោគឱ្យឮ និងច្បាស់ៗចំនួនពីរដងមុននឹងឱ្យសិស្សសរសេរ
- គ្រូបំបែកឃ្លា ប្រយោគដែលវែងជាផ្នែក ដើម្បីឱ្យសិស្សងាយស្តាប់ និងសរសេរតាម
- គ្រូអានពាក្យ ឬឃ្លាខ្លីៗបីដង ហើយឱ្យសិស្សម្នាក់ថាតាម ក្នុងកំឡុងពេលសិស្សទាំងអស់សរសេរនៅលើក្តារឆ្នួន ឬសៀវភៅសរសេរ
- នៅពេលសរសេរចប់ គ្រូត្រូវអានម្តងទៀតដើម្បីឱ្យសិស្សធ្វើតផ្ទាត់កិច្ចការឡើងវិញ
- គ្រូត្រួតពិនិត្យកិច្ចការសិស្ស ឬប្រមូលកិច្ចការសិស្សមកកែដាក់ពិន្ទុ ឬអាចឱ្យសិស្សប្តូរកិច្ចការគ្នាកែដើម្បីរកមើលកំហុសឆ្គង និងកែលម្អ។
- គ្រូចម្លងពាក្យ ឃ្លា ឬប្រយោគ អត្ថបទដែលត្រឹមត្រូវដាក់លើក្តារខៀន(ត្រៀមលក្ខណៈមុន)។

៥.៦. ការលេងល្បែងសិក្សា៖

- គ្រូគួរជ្រើសរើសល្បែងសិក្សាដែលឆ្លើយតប ឬគាំទ្រទៅតាមខ្លឹមសារមេរៀន
- គ្រូពន្យល់ណែនាំពីរបៀបលេងល្បែងសិក្សា។

  ឧទាហរណ៍៖ ល្បែងខ្ទប់ពាក្យ (slap the board):
  - គ្រូសរសេរពាក្យដែលបានរៀនរួចនៅលើក្តារខៀន
  - គ្រូជ្រើសរើសសិស្សពីរនាក់ដើម្បីឡើងមកលេងល្បែងសិក្សា
  - គ្រូហៅពាក្យ ហើយសិស្សជាអ្នកខ្ទប់ពាក្យ
  - អ្នកដែលខ្ទប់បានមុនគេជាអ្នកឈ្នះ
  - អ្នកដែលឈ្នះចំនួនប្រាំដងត្រូវទទួលបានការលើកទឹកចិត្ត។

៥.៧. ការប្រើប្រាស់ភាសាប្រចាំថ្ងៃនៅក្នុងពេលបង្រៀន (Classroom Language)៖

គ្រូបង្រៀនត្រូវតែប្រើប្រាស់ភាសាងាយៗនៅពេលបង្រៀន ដើម្បីឱ្យសិស្សមានទម្លាប់ក្នុងការស្តាប់និងនិយាយ ដោយមិនចាំបាច់ពន្យល់បកស្រាយនៅពាក្យដែលបានយកមកប្រើប្រាស់។ ពាក្យទាំងនោះមានដូចជា: Look at the board, write on the board, open the book, close the book, stand up, sit down, be quiet, keep silent, raise your hand, repeat after me, please come to the board, work with your partner, look at the picture, write in your book, copy the lesson into your notebook, review the lesson, etc.

គំរូកិច្ចតែងការបង្រៀនសម្រាប់ម៉ោងទី១

Sample Lesson Plan for the First Hour

Teacher គ្រូបង្រៀន: _____ **Time** ម៉ោង: **40 Minutes**

Date កាលបរិច្ឆេទ: _____

Grade ថ្នាក់ទី: **6**

Chapter 1 ជំពូកទី១: ***Time And Activities***

Unit 1 មេរៀនទី១: ***Greeting And Introduction*** **(Pages 1-2 in textbook)**

Aim គោលបំណង: Use greeting words to greet people correctly and introduce someone to others.

Objective វត្ថុបំណង: By the end of the lesson, the students will be able to:

K(Knowledge) វិជ្ជាសម្បទា: Identify greeting words when saying Good morning, Good afternoon and Good evening.

S (Skills) បំណិនសម្បទា: Use greeting words with each other in English at the right times.

A (Attitude) ចរិយាសម្បទា: Be polite when meeting each other.

Resources ធនធានសម្ភារៈ: small board, flashcards, Grade 6 Textbook, Grade 6 Teacher's Guide, pictures for morning, afternoon, and evening.

(Teacher = T, Students = Ss, Question = Q, Answer = A)

Teacher's Activities	*Contents*	*Students' Activities*
• Greet the Students • Check Sanitation/hygiene • Check attendance • Ask Ss to read and translate the words: flood, North, East, South, West, loud, ground	***Warm up/Revisions (5mns)*** • Greeting • How to greet each other • Review flood, North, East, South, West, loud, ground	• Reply to the greeting • Reply to the T • Listen and repeat
• Introduce a new topic • Elicit new words from Ss by showing the pictures and asking them what this is in English • Say the words clearly 2 or 3 times • Ask Ss to spell the words • Ask Ss to repeat the words until they can say them correctly	***New Knowledge (10mns)*** • Greeting And Introduction • Vocabulary - morning - afternoon - evening	• Guess and try to answer • Spell the words

• Play *Matching* game: - Stick the pictures on the board - Call Ss to write the words next to the pictures - Correct them	- m-o-r-n-i-n-g - a-f-t-e-r-n-o-o-n - e-v-e-n-i-n-g - morning - afternoon - evening	• Write the words next to the pictures
• Write the words on the board • Ask Ss to read the words • Play *Erase & Remember* game: - Ask Ss to read a word and erase it - Keep pointing to the empty spaces to see if Ss can remember what was written • Ask Ss to practice spelling the words in pairs • Help the pairs that need support	***Guided Practice (10mns)*** • B. Spelling - morning - afternoon - evening - fine - bad	• Read the words • Participate in game • Work in pairs
• Choose 2 Ss to model the dialogue • Ask the next 2 Ss to repeat the dialogue with support • Let Ss practice the dialogue in pairs and use their own names • Ask selected pairs to show their dialogue to the class	***Independent Practice (10mns)*** • C. Conversation - Good morning! - How old are you? - What grade are you in?	• Listen to T • Model the dialogue • Work in pairs to practice the dialogue • 2 Ss act out the dialogue • Come to the front to perform the dialogue and others listen
• Check whether Ss know the sentence structures	***Review and Closure (5mns)*** • Review sentence structures and check their understanding	• Listen to T

• Set homework for Ss to draw and write the words: morning, afternoon, and evening in their notebooks	• Homework: - Write morning, afternoon, and evening 3 to 5 times - Draw a picture of each word	• Write each word 3 to 5 times and draw a picture of them

គំរូកិច្ចតែងការបង្រៀនសម្រាប់ម៉ោងទី២

Sample Lesson Plan for the Second Hour

Teacher គ្រូបង្រៀន: _____ **Time** ម៉ោង: **40 Minutes**

Date កាលបរិច្ឆេទ: _____

Grade ថ្នាក់ទី: **6**

Chapter 1 ជំពូកទី១: ***Time and Activities***

Unit 1 មេរៀនទី១: ***Greetings and Introduction*** **(Pages 3-4 in textbook)**

Aim គោលបំណង: Use greeting words to greet people correctly and introduce someone to others.

Objective វត្ថុបំណង: By the end of this lesson, students will be able to:

K(Knowledge) វិជ្ជាសម្បទា: Describe the rule to make contractions of the verb *to be*

S (Skills) បំណិនសម្បទា: Apply contractions of the verb *to be* correctly

A (Attitude) ចរិយាសម្បទា:: Be careful to use contractions of the verb *to be*

Resources ធនធានសម្ភារៈ: small board, flashcards, Grade 6 textbook, pictures for morning, afternoon, and evening

(Teacher = T, Students = Ss, Question = Q, Answer = A)

Teacher's Activities សកម្មភាពគ្រូ	***Contents*** ខ្លឹមសារ	***Students' Activities*** សកម្មភាពសិស្ស
• Check the attendance • Ask Ss what they have learned in the previous lesson - Have Ss tell the words and translate them into Khmer	***Warm up/ Revisions (5mns)*** - morning - afternoon - evening	• Listen to T • Say the words and translate them into Khmer: - morning: ព្រឹក - afternoon: រសៀល - evening: ល្ងាច
• Introduce the	***New Knowledge (5mns)***	

contraction form of the verb to be • Write the contractions on the board and read them • Have Ss repeat them	• Contractions - I am = I'm - Name is = Name's - What is= What's	• Listen and observe • Repeat after T • Copy them into notebooks
	Guided Practice (15mns)	
• Elicit the new vocabulary from the Ss by showing the pictures and pointing to the realia • Translate the words	• E. Reading - mathematics: គណិតវិទ្យា - library:បណ្ណាល័យ - playground:សួនកុមារ - garden:សួនច្បារ - football field:តារាងបាល់ទាត់	• Listen to T • Try to answer • Repeat after T • Copy into notebooks
• Read the text 2 times • Ask one Ss to read the text loudly • Have Ss read the text silently		• Listen to T & another Ss • Read the text silently
• Ask Ss to read the Qs from 1 to 4 • Ask the Ss to read the text again and then answer the Qs from 1 to 4 in groups • Ask the Example Q and ask Ss to answer on small boards • In pairs, Ss answer the other Qs • Support Ss who need help • Check the As	1. What is her brother's name? Her brother's name is Vichet. 2. What subject is her brother good at? Her brother is good at Mathematics. 3. What grade is her sister in? Her sister is in Grade 5. 4. How do they go to school? They go to school by bicycle.	• Answer the Qs and hold up their board • Work in pairs to answer the Qs • Check the As
	Independent Practice (10mns)	
• Review contraction form of verb *to be*	- I am = I'm - Name is = Name's - What is= What's	• Listen to T
• Ask Ss to complete the missing words in exercise F and practice the dialogue with their partner • Support Ss who need	• F. Speaking A. How are you, name? B. I'm fine. Thank you. A. How old are you?	• Do the exercise • Work in pairs to practise the dialogue

help	B. I'm 12 years old. A. What grade are you in? B. I'm in Grade 6.	
• Check whether Ss understood the lesson • Have Ss make a positive form and Q form with verb *to be*	***Review and Closure (5mns)*** • Positive Form - They're farmers. - He's a student. - She's a girl. - I'm a student in Grade 6. • Question Form - Are they farmers? - Is he a student? - Is she a girl? - Are you a student in Grade 6?	• Listen to T • Practise making positive and Q forms with partners
• Ask Ss to write 5 sentences about themselves	• G. Writing - Write 5 sentences: Ex: I am 12 years old. 1. _____ 2. _____ 3. _____ 4. _____ 5. _____	• Write 5 sentences about themselves • Give the As to T
• Ask Ss to read Unit 2 on page 12 at home		• Read Unit 2 at home

Chapter 1
ជំពូកទី១
TIME AND ACTIVITIES
ពេលវេលា និងសកម្មភាព

Unit 1: Greeting And Introduction
មេរៀនទី១៖ កិច្ចស្វាគមន៍ និងការណែនាំខ្លួន
រយៈពេល ២ ម៉ោង

១. Objectives វត្ថុបំណង

- អានពាក្យ morning, afternoon និង evening
- សរសេរ និងប្រកបពាក្យ morning, afternoon និង evening
- បណ្តុះស្មារតីសិស្សឱ្យក្លាហានក្នុងការអនុវត្តសរសេរពាក្យ ការប្រើទម្រង់ខ្លី I'm, name's និង what's ការអានអត្ថបទខ្លីៗ ការសន្ទនា និងការបង្កើតសំណួរចម្លើយ

២. Teaching Materials សម្ភារៈបង្រៀន

- សៀវភៅសិស្ស និងឯកសារជំនួយការបង្រៀនភាសាអង់គ្លេស
- រូបភាព និងបណ្តុំពាក្យ morning, afternoon និង evening
- ក្តារខៀន ក្តារឆ្នួន និងហ្វឺត ឬដីស
- អាត់សំឡេង CD, ម៉ាស៊ីនចាក់ DVD ឬ Smart Phone

៣. Teaching Process លំនាំនៃការបង្រៀន

A. Vocabulary រៀនពាក្យ

Look at the picture, listen and repeat.
ចូរមើលរូបភាព ស្តាប់ និងថាតាម

គ្រូ៖ - បង្ហាញរូបភាព និងសរសេរពាក្យនៅលើក្តារខៀន ហើយបិទរូបភាពនៅពីលើ ឬក្រោមពាក្យ morning, afternoon និង evening
- អានពាក្យឱ្យសិស្សស្តាប់ និងថាតាម
- ឱ្យសិស្សអានពាក្យជាជួរ និងក្រុម
- បកប្រែពាក្យជាភាសាខ្មែរ morning = ពេលព្រឹក, afternoon = ពេលរសៀល និង evening = ពេលល្ងាច

B. Spelling ការប្រកបពាក្យ

Spell each word in the box with your partner.
ចូរប្រកបពាក្យនីមួយៗក្នុងប្រអប់ជាមួយដៃគូរបស់អ្នក

គ្រូ៖ - ឱ្យសិស្សប្រកបពាក្យជាបុគ្គល ឬក្រុម
- ឱ្យសិស្សម្តងពីរនាក់ៗប្រកបពាក្យ

ឧទាហរណ៍៖ សិស្ស (A) និយាយថា please spell the word ***morning.***

ហើយសិស្ស (B) ថា ***morning*** I spell ***m-o-r-n-i-n-g.***

- សរសេរពាក្យលើក្តារខៀនឱ្យសិស្សអានជាជួរ និងក្រុម
- ឱ្យសិស្សអនុវត្តបន្តជាមួយពាក្យ afternoon, evening, fine និង bad
- ណែនាំសិស្សឱ្យលេងល្បែង ***Erase and Remember*** *(លុប ហើយចងចាំ)*
- ឱ្យសិស្សសរសេរពាក្យ morning, afternoon និង evening លើក្តារខៀន

C. Conversation ការសន្ទនា

១. Listen to your teacher and repeat.

ចូរស្តាប់ និងថាតាមគ្រូរបស់អ្នក

គ្រូ៖ - អានសន្ទនាឱ្យសិស្សស្តាប់ និងថាតាមជាក្រុម

- ចែកសិស្សជាពីរក្រុមឱ្យសន្ទនាគ្នា
- ឱ្យសិស្សពីរនាក់សន្ទនាគ្នាជាគំរូដោយប្រើឈ្មោះផ្ទាល់ខ្លួន

២. Listen again and practise with your partner.

ចូរស្តាប់ម្តងទៀត រួចអនុវត្តជាមួយដៃគូរបស់អ្នក

គ្រូ៖ - អានសន្ទនាឱ្យសិស្សស្តាប់ម្តងទៀត រួចឱ្យសិស្សសន្ទនាតាមលំនាំ និងព័ត៌មានផ្ទាល់ខ្លួន

D. Language Focus ការផ្តោតលើភាសា

កិរិយាស័ព្ទ ***To be (am/is/are)*** បង្កើតប្រយោគស្រប និងសំណួរ

ប្រយោគស្រប	ប្រយោគសំណួរ
I***'m*** Raksa.	How ***are*** you?
My name***'s*** Darith.	What***'s*** your name?
This ***is*** Nary.	

គ្រូ៖ - សរសេរឧទាហរណ៍លើក្តារខៀន រួចណែនាំសិស្សពីរបៀបសរសេរអក្សរកាត់

(I'm = I am, He's = He is, You're = You are, ...)

E. Reading អំណាន

១ . Listen to your teacher and repeat.

ចូរស្តាប់ និងថាតាមគ្រូរបស់អ្នក

គ្រូ៖ - ចម្លងអត្ថបទលើក្តារខៀន ឬបិទផ្ទាំងអត្ថបទ

- ឱ្យសិស្សទាំងអស់អានអត្ថបទស្ងាត់ និងប្រាប់នូវពាក្យពិបាក ឬពាក្យថ្មី
- អាន និងពន្យល់ពាក្យពិបាក
- ឱ្យសិស្សអានពាក្យ ឬអត្ថបទជាបុគ្គល ឬក្រុម
- ឱ្យសិស្សប្រកបពាក្យជាបុគ្គល ឬក្រុម
- ឱ្យសិស្សម្នាក់អានអត្ថបទ និងម្នាក់ទៀតបកប្រែជាភាសាខ្មែរ

២. Read the text again and answer the questions.

ចូរអានអត្ថបទឡើងវិញ រួចឆ្លើយសំណួរ

គ្រូ៖ - ឱ្យសិស្សម្នាក់អានអត្ថបទ និងម្នាក់ទៀតបកប្រែជាភាសាខ្មែរ

- ឱ្យសិស្សអានអត្ថបទស្ងាត់រៀងៗខ្លួន បន្ទាប់មកសួរ និងឆ្លើយសំណួរជាដៃគូ

ឧទាហរណ៍៖ Who is in Grade 6? Ratha is in Grade 6.

- ឱ្យសិស្សធ្វើងផ្ទាត់ចម្លើយទាំងអស់

ចម្លើយ៖ 1. Her brother's name is Vichet./He is Vichet.

2. Her brother is good at Mathematics./He is good at Mathematics.
3. Her sister is in Grade 5. /She is in Grade 5.
4. They go to school by bicycle.

F. Speaking ការនិយាយ

Practise with your partner.

ចូរអនុវត្តជាមួយដៃគូរបស់អ្នក

គ្រូ៖ - រំឭកសិស្សឱ្យចេះប្រើទម្រង់ខ្លី និងបំពេញចន្លោះដោយប្រើព័ត៌មានផ្ទាល់ខ្លួន

- ឱ្យសិស្សសន្ទនាជាដៃគូ

ឧទាហរណ៍៖ Good morning! My name is Bol.

Good morning! I'm Nita.

G. Writing សំណេរ

Write five sentences about yourself in your notebook.

ចូរសរសេរឱ្យបានប្រាំប្រយោគអំពីខ្លួនរបស់អ្នកក្នុងសៀវភៅសរសេររបស់អ្នក

គ្រូ៖ ពន្យល់បានច្បាស់ពីរបៀបបង្កើតប្រយោគ

ឧទាហរណ៍៖ I am 12 years old.

ចម្លើយ៖ 1. I am a student.

2. I am fine.
3. I am very good at Khmer.
4. I have one brother and two sisters.
5. I am a hard working student.

Remember ចូរចងចាំ

គ្រូ៖ - ប្រាប់សិស្សឱ្យចាំពាក្យ morning, afternoon, evening, hello, bad, fine និង good

- ឱ្យសិស្សបង្កើតប្រយោគស្រប និងប្រយោគសំណួរ

ប្រយោគស្រប	ប្រយោគសំណួរ
I'***m*** Raksa.	How ***are*** you?
My name***'s*** Darith.	What***'s*** your name?
This ***is*** Nary.	

Unit 2: Telling The Time
មេរៀនទី២៖ ការប្រាប់ពីពេលវេលា
រយៈពេល ២ ម៉ោង

១. Objectives វត្ថុបំណង
- អានពាក្យ និងឃ្លា clock, quarter to, half past, quarter past និង o'clock
- សរសេរ និងប្រកប clock, quarter to, half past, quarter past និង o'clock
- បណ្តុះស្មារតីសិស្សឱ្យក្លាហានក្នុងការអនុវត្តសរសេរពាក្យ ការអានអត្ថបទខ្លីៗ ការសន្ទនា និងការបង្កើតសំណួរចម្លើយ

២. Teaching Materials សម្ភារៈបង្រៀន
- សៀវភៅសិស្ស និងឯកសារជំនួយការបង្រៀនភាសាអង់គ្លេស
- រូបភាព និងបណ្តាពាក្យ clock, quarter to, half past, quarter to, quarter past និង o'clock
- ក្តារខៀន ក្តារឆ្នួន និងហ្វឺត ឬដីស
- ខ្សែអាត់សំឡេង CD, ម៉ាស៊ីនចាក់ CD ឬ Smart Phone

៣. Teaching Process លំនាំបង្រៀន
A. Vocabulary រៀនពាក្យ
Look at the pictures. Listen and repeat.
ចូរមើលរូបភាព ស្តាប់ និងថាតាម

គ្រូ៖ - បិទបណ្តាពាក្យលើក្តារខៀន និងឱ្យសិស្សសរសេរពាក្យ clock, half past, quarter to, quarter past និង o'clock ពីលើ ឬក្រោមរូបភាព
- អានពាក្យឱ្យសិស្សស្តាប់ និងថាតាម
- បកប្រែពាក្យជាភាសាខ្មែរ clock = នាឡិកា, quarter to = ខ្វះ១៥នាទីម៉ោង ..., half past = ម៉ោង ... កន្លះ, quarter past = ម៉ោង ... លើស១៥នាទី, o'clock = ម៉ោង

B. Spelling ការប្រកបពាក្យ
Spell each word in the box with your partner.
ចូរប្រកបពាក្យនីមួយៗក្នុងប្រអប់ជាមួយដៃគូរបស់អ្នក

គ្រូ៖ - ឱ្យសិស្សម្តងពីរនាក់ៗប្រកបពាក្យ

ឧទាហរណ៍៖ សិស្ស (A) និយាយថា please spell the word ***clock.***
ហើយសិស្ស (B) ថា ***clock*** I spell ***c-l-o-c-k.***
- សរសេរពាក្យលើក្តារខៀនឱ្យសិស្សអានទាំងអស់គ្នា
- ឱ្យសិស្សអនុវត្តបន្តជាមួយពាក្យ half, o'clock, quarter និង past
- លេងល្បែង ***Erase and Remember*** (អនុវត្តដូចមេរៀនមុន) ឬ **Matching** (ផ្គូផ្គង)

C. Conversation ការសន្ទនា

១. Listen to your teacher and repeat.

ចូរស្តាប់ និងថាតាមគ្រូរបស់អ្នក

គ្រូ៖ - អានសន្ទនាឱ្យសិស្សស្តាប់ និងថាតាមជាក្រុម

- ចែកសិស្សជាពីរក្រុមឱ្យសន្ទនាគ្នា
- ឱ្យសិស្សពីរនាក់សន្ទនាគ្នាជាគំរូ

២. Listen again and practise with your partner.

ចូរស្តាប់ម្តងទៀត និងអនុវត្តជាមួយដៃគូ

គ្រូ៖ - អានសន្ទនាឱ្យសិស្សស្តាប់ម្តងទៀត រួចឱ្យសិស្សសន្ទនាតាមលំនាំ និងព័ត៌មានផ្ទាល់ខ្លួន

D. Language Focus ការផ្តោតលើភាសា

What time is it?

តើម៉ោងប៉ុន្មាន ?

គ្រូ៖ ពន្យល់សិស្សពីរបៀបសួរ និងឆ្លើយ និងឱ្យសិស្សអនុវត្តជាក្រុម

សំណួរ	ចម្លើយ
- What time is it?	- It is quarter to ten. - It is quarter past ten.

E. Reading អំណាន

១ . Listen to your teacher and repeat.

ចូរស្តាប់ និងថាតាមគ្រូរបស់អ្នក

គ្រូ៖ - ចម្លងអត្ថបទលើក្តារខៀន ឬបិទផ្ទាំងអត្ថបទ

- ឱ្យសិស្សទាំងអស់អានអត្ថបទស្ងាត់ និងប្រាប់នូវពាក្យពិបាក ឬពាក្យថ្មី
- អាន និងពន្យល់ពាក្យពិបាក
- ឱ្យសិស្សអានពាក្យ ឬអត្ថបទជាបុគ្គល ឬក្រុម
- ឱ្យសិស្សប្រកបពាក្យជាបុគ្គល ឬក្រុម
- ឱ្យសិស្សម្នាក់អានអត្ថបទ និងម្នាក់ទៀតបកប្រែជាភាសាខ្មែរ

២. Read the text again and answer the questions.

ចូរអានអត្ថបទម្តងទៀត រួចឆ្លើយសំណួរ

គ្រូ៖ - ឱ្យសិស្សម្នាក់អានអត្ថបទ និងម្នាក់ទៀតបកប្រែជាភាសាខ្មែរ

- ឱ្យសិស្សអានអត្ថបទស្ងាត់រៀងៗខ្លួន បន្ទាប់សួរ និងឆ្លើយសំណួរជាដៃគូ

ឧទាហរណ៍៖ What time does Nita have breakfast?

She has breakfast at half past six.

- ឱ្យសិស្សឱ្យសិស្សផ្លាស់ប្តូរចម្លើយទាំងអស់ទាំងអស់គ្នា

ចម្លើយ៖ 1. She cleans the classroom at quarter to seven.

2. She studies Science from seven to eight o'clock.

3. She has a break at quarter to eight.
4. She goes home at ten past eleven.

F. Speaking ការនិយាយ

Practise with your partner.
ចូរអនុវត្តជាមួយដៃគូរបស់អ្នក

គ្រូ៖ - ឱ្យសិស្សបំពេញចន្លោះដោយខ្លួនឯង បន្ទាប់មកឱ្យសិស្សធ្វើងផ្ទាត់ចម្លើយទាំងអស់ជាមួយដៃគូ
- ឱ្យសិស្សសន្ទនាគ្នាជាដៃគូអំពីម៉ោងក្នុងប្រអប់

ឧទាហរណ៍៖ What is the time? It's seven o'clock.

ចម្លើយ៖ 1. It's quarter past seven.
2. It's half past seven.
3. It's quarter to eight.
4. It's five to eight.
5. It's five past seven.

G. Writing សំណេរ

Write the time below in words in your notebook.
ចូរសរសេរម៉ោងខាងក្រោមជាពាក្យក្នុងសៀវភៅសរសេររបស់អ្នក

6:30	7:00	8:30	9:45	10:55	11:05

គ្រូ៖ ពន្យល់សិស្សឱ្យសរសេរម៉ោងក្នុងប្រអប់ជាពាក្យ

ឧទាហរណ៍៖ It's ***half past six***.

ចម្លើយ៖ 1. It's ***seven o'clock***.
2. It's ***half past eight***.
3. It's ***quarter to ten***.
4. It's ***five to eleven***.
5. It's ***five past eleven***.

Remember ចូរចងចាំ

គ្រូ៖ - ប្រាប់សិស្សឱ្យចាំពាក្យ clock, half, past, o'clock, time, quarter to និង quarter past
- ប្រាប់សិស្សថា ***to*** ខ្វះ ***past*** លើស
- ឱ្យសិស្សសួរ និងឆ្លើយសំណួរ

សំណួរ	ចម្លើយ
- What time is it?	- It is quarter to ten. - It is quarter past ten.

Unit 3: Feeling Happy
មេរៀនទី៣៖ អារម្មណ៍សប្បាយរីករាយ
រយៈពេល ២ ម៉ោង

១. Objectives វត្ថុបំណង
- អានពាក្យ watch, television, school, bath និង happy
- សរសេរ និងប្រកបពាក្យ watch, television, school, bath និង happy
- បណ្តុះស្មារតីសិស្សឱ្យក្លាហានក្នុងការអនុវត្តសរសេរពាក្យ ការអានអត្ថបទខ្លីៗ ការសន្ទនា និងការបង្កើតសំណួរចម្លើយ

២. Teaching Materials សម្ភារៈបង្រៀន
- សៀវភៅសិស្ស និងឯកសារជំនួយការបង្រៀនភាសាអង់គ្លេស
- រូបភាព និងបណ្តាពាក្យ watch, television, school, bath និង happy
- ក្តារខៀន ក្តារឆ្នួន និងហ្វឺត ឬដីស
- អាត់សំឡេង CD, ម៉ាស៊ីនចាក់ DVD ឬ Smart Phone

៣. Teaching Process លំនាំបង្រៀន
A. Vocabulary រៀនពាក្យ
Look at the pictures. Listen and repeat.
ចូរមើលរូបភាព ស្តាប់ និងថាតាម

គ្រូ៖ - បង្ហាញរូបភាព និងសរសេរពាក្យលើក្តារខៀន ហើយបិទរូបភាពនៅលើ ឬក្រោមពាក្យ watch, television, school, bath និង happy រួចអានពាក្យឱ្យបាន៣ដងឱ្យសិស្សស្តាប់ បន្ទាប់មកឱ្យសិស្សថាតាម រួចឱ្យសិស្សអានពាក្យជាជួរ និងជាក្រុម បកប្រែពាក្យជាភាសាខ្មែរ
watch = មើល, television = ទូរទស្សន៍, school = សាលារៀន,
bath (take a bath) = ងូតទឹក និង happy = សប្បាយ

B. Spelling ការប្រកបពាក្យ
Spell each word in the box with your partner.
ចូរប្រកបពាក្យនីមួយៗក្នុងប្រអប់ជាមួយដៃគូ

គ្រូ៖ - ឱ្យសិស្សម្តងពីរនាក់ៗប្រកបពាក្យ

ឧទាហរណ៍៖ សិស្ស (A) និយាយថា please spell the word ***bath***
ហើយសិស្ស (B) ថា bath I spell ***b-a-t-h*** រួចគ្រូសរសេរពាក្យទាំងនេះនៅលើក្តារខៀន បន្ទាប់មកឱ្យសិស្សអានទាំងអស់គ្នា

- ឱ្យសិស្សអនុវត្តបន្តជាមួយពាក្យ watch, television, school និង happy
- លេង ***Guess the Word*** (ទាយពាក្យ)

C. Conversation ការសន្ទនា
១. Listen to your teacher and repeat.

ចូរស្តាប់ និងថាតាមគ្រូរបស់អ្នក

គ្រូ៖ - អានសន្ទនាឱ្យសិស្សស្តាប់ និងថាតាមជាក្រុម

- ចែកសិស្សជាពីរក្រុមឱ្យសន្ទនាគ្នា
- ឱ្យសិស្សពីរនាក់សន្ទនាគ្នាជាគំរូ
- ឱ្យសិស្សពីរនាក់ឡើងសន្ទនាដោយប្រើពេលវេលាជាក់ស្តែង

២.Listen again and practise with your partner.

ចូរស្តាប់ម្តងទៀត និងអនុវត្តជាមួយដៃគូ

គ្រូ៖ - អានសន្ទនាឱ្យសិស្សស្តាប់ម្តងទៀត រួចឱ្យសិស្សសន្ទនាតាមលំនាំ និងព័ត៌មានផ្ទាល់ខ្លួន

D. Language Focus ការផ្តោតលើភាសា

Present simple with Wh___ questions.

បច្ចុប្បន្នកាលធម្មតាជាមួយ ***Wh___questions***

គ្រូ៖ - ពន្យល់សិស្សពីការបង្កើតប្រយោគបច្ចុប្បន្នកាលធម្មតាជាមួយ ***Wh__ questions.***

សំណួរ	ចម្លើយ
What time do you get up?	I get up at five o'clock.
How do you go to school?	I go to school on foot.

E. Reading អំណាន

១ . Listen to your teacher and repeat.

ចូរស្តាប់ និងថាតាមគ្រូរបស់អ្នក

គ្រូ៖ - ចម្លងអត្ថបទលើក្តារខៀន ឬបិទផ្ទាំងអត្ថបទ

- ឱ្យសិស្សទាំងអស់អានអត្ថបទស្ងាត់ និងប្រាប់នូវពាក្យពិបាក ឬពាក្យថ្មី
- អាន និងពន្យល់ពាក្យពិបាក
- ឱ្យសិស្សអានពាក្យ ឬអត្ថបទជាបុគ្គល ឬក្រុម
- ឱ្យសិស្សប្រកបពាក្យជាបុគ្គល ឬក្រុម
- ឱ្យសិស្សម្នាក់អានអត្ថបទ និងម្នាក់ទៀតបកប្រែជាភាសាខ្មែរ

២. Read the text again and answer the questions.

ចូរអានអត្ថបទម្តងទៀត រួចឆ្លើយសំណួរ

គ្រូ៖ - ឱ្យសិស្សម្នាក់អានអត្ថបទ និងម្នាក់ទៀតបកប្រែជាភាសាខ្មែរ

- ឱ្យសិស្សអានអត្ថបទស្ងាត់រៀងៗខ្លួន បន្ទាប់មកសួរ និងឆ្លើយសំណួរជាដៃគូ

ឧទាហរណ៍៖ What grade does Dara study in?

He studies in Grade 6.

- ឱ្យសិស្សធ្វើងផ្ទាត់ចម្លើយទាំងអស់ទាំងអស់គ្នា

ចម្លើយ៖ 1. Dara and his sister go to school by bicycle.

2. He spends his free time on his studies and family.
3. After dinner, he reads books and does homework.

4. His parents are happy because he is a smart student, all his classmates love him, and he has good performance in school.

F. Speaking ការនិយាយ

Look at the pictures and practise with your partner.
ចូរមើលរូបភាព រួចអនុវត្តជាមួយដៃគូរបស់អ្នក

គ្រូ៖ - បង្ហាញរូបភាពឱ្យសិស្សនិយាយពាក្យ play basketball, take a bath និង watch television ដោយប្រើសំណួរ

ឧទាហរណ៍៖ What time do they play basketball?
They play basketball at 5 o'clock.

- ឱ្យសិស្សបន្តសំណួរលើរូបភាពពីរផ្សេងទៀត

G. Writing សំណេរ

Write five enjoyable activities with the times you do them in your notebook.
ចូរសរសេរបានប្រាំសកម្មភាពដែលធ្វើឱ្យអ្នករីករាយក្នុងសៀវភៅសរសេររបស់អ្នក

គ្រូ៖ - ពន្យល់បានច្បាស់ពីរបៀបដែលត្រូវបង្កើតប្រយោគ

ឧទាហរណ៍៖ I play football with my friends at three o'clock in the evening.

ចម្លើយ៖ 1. I swim every Sunday with my friends at four o`clock.
2. I listen to music in the evening at seven o`clock.
3. I visit Angkor Wat Temple on my weekends.
4. I watch television with my family members at lunchtime.
5. I read storybooks in the evening at nine o`clock.

Remember ចូរចងចាំ

គ្រូ៖ - ប្រាប់សិស្សឱ្យចាំពាក្យ bath, happy, television, school និង watch
- ពន្យល់សិស្សពីការបង្កើតប្រយោគបច្ចុប្បន្នកាលធម្មតាជាមួយ ***Wh__ questions.***

សំណួរ	ចម្លើយ
What time do you get up?	I get up at five o'clock.
How do you go to school?	I go to school on foot.

Unit 4: Time At Home

មេរៀនទី៤៖ ពេលវេលានៅផ្ទះ

រយៈពេល ២ ម៉ោង

១. Objectives វត្ថុបំណង

- អានពាក្យ wash, eat, brush, clean និង cook
- សរសេរ និងប្រកបពាក្យ wash, eat, brush, clean និង cook

- បណ្តុះស្មារតីសិស្សឱ្យក្លាហានក្នុងការអនុវត្តសរសេរពាក្យ ការអានអត្ថបទខ្លីៗ ការសន្ទនា និងការបង្កើតសំណួរចម្លើយ

២. Teaching Materials សម្ភារៈបង្រៀន

- សៀវភៅសិស្ស និងឯកសារជំនួយការបង្រៀនភាសាអង់គ្លេស
- រូបភាព និងបណ្តាពាក្យ wash, eat, brush, clean និង cook
- អាត់សំឡេង CD, ម៉ាស៊ីនចាក់ DVD ឬ Smart Phone

៣. Teaching Process លំនាំបង្រៀន

A. Vocabulary រៀនពាក្យ

Look at the pictures. Listen and repeat.
ចូរមើលរូបភាព ស្តាប់ និងថាតាម

គ្រូ៖ - បង្ហាញរូបភាព ឬសរសេរពាក្យក្នុងប្រអប់លើក្តារខៀន ហើយបិទរូបភាពនៅលើ ឬក្រោមពាក្យ wash, eat, brush, clean និង cook រួចអានឱ្យសិស្សស្តាប់ បន្ទាប់មកឱ្យសិស្សថាតាម

- បកប្រែពាក្យជាភាសាខ្មែរ wash = លាង, eat = ញុំ, brush = ដុស, clean = សម្អាត និង cook = ដាំ ឬ ចំអិន

B. Spelling ការប្រកបពាក្យ

Spell each word in the box with your partner.
ចូរប្រកបពាក្យនីមួយៗក្នុងប្រអប់ជាមួយដៃគូរបស់អ្នក

គ្រូ៖ - ឱ្យសិស្សម្តងពីរនាក់ៗប្រកបពាក្យ

ឧទាហរណ៍៖ សិស្ស (A) និយាយថា Please spell the word ***wash***
ហើយសិស្ស (B) ថា ***wash*** I spell ***w-a-s-h*** រួចសរសេរនៅលើក្តារខៀន ហើយឱ្យសិស្សអានទាំងអស់គ្នា

- ឱ្យសិស្សអនុវត្តបន្តជាមួយពាក្យ eat, brush, clean និង cook

C. Conversation ការសន្ទនា

១. Listen to your teacher and repeat.
ចូរស្តាប់ និងថាតាមគ្រូរបស់អ្នក

គ្រូ៖ - អានសន្ទនាឱ្យសិស្សស្តាប់ និងថាតាមជាក្រុម
- ចែកសិស្សជាពីរក្រុមឱ្យសន្ទនាគ្នា
- ឱ្យសិស្សពីរនាក់សន្ទនាគ្នាជាគំរូ

ឧទាហរណ៍៖ - When do you stay at home?
- I usually stay at home in the afternoon.

២. Listen again and practise with your partner.
ចូរស្តាប់ម្តងទៀត រួចអនុវត្តជាមួយដៃគូ

គ្រូ៖ - អានសន្ទនាឱ្យសិស្សស្តាប់ម្តងទៀត រួចឱ្យសិស្សសន្ទនាតាមលំនាំ និងព័ត៌មានផ្ទាល់ខ្លួន

D. Language Focus ការផ្តោតលើភាសា

Present simple with times of the day.
បច្ចុប្បន្នកាលធម្មតាទៅតាមពេលវេលានៃថ្ងៃ

គ្រូ៖ ពន្យល់សិស្សឱ្យយល់ពីកាលដែលត្រូវប្រើជាមួយពេលវេលានៃថ្ងៃ

សំណួរ	ចម្លើយ
-***When*** **do** you stay at home?	-I ***stay*** at home in the ***afternoon.***
-***What*** **do** you do in the ***morning?***	-I ***wash*** my face, ***brush*** my teeth and ***clean*** the house.
-***What*** **does** she do in the ***evening?***	-She ***cooks, has*** dinner and ***studies.***

E. Reading អំណាន

១. Listen to your teacher and repeat.
ចូរស្តាប់ និងថាតាមគ្រូរបស់អ្នក

គ្រូ៖ - ចម្លងអត្ថបទលើក្តារខៀន ឬបិទផ្ទាំងអត្ថបទ
- ឱ្យសិស្សទាំងអស់អានអត្ថបទស្ងាត់ និងប្រាប់នូវពាក្យពិបាក ឬពាក្យថ្មី
- អាន និងពន្យល់ពាក្យពិបាក
- ឱ្យសិស្សអានពាក្យ ឬអត្ថបទជាបុគ្គល ឬក្រុម
- ឱ្យសិស្សប្រកបពាក្យជាបុគ្គល ឬក្រុម
- ឱ្យសិស្សម្នាក់អានអត្ថបទ និងម្នាក់ទៀតបកប្រែជាភាសាខ្មែរ

២. Read the text again and answer the questions
ចូរអានអត្ថបទម្តងទៀត រួចឆ្លើយសំណួរ

គ្រូ៖ - ឱ្យសិស្សម្នាក់អានអត្ថបទ និងម្នាក់ទៀតបកប្រែជាភាសាខ្មែរ
- ឱ្យសិស្សអានអត្ថបទស្ងាត់រៀងៗខ្លួន បន្ទាប់មកសួរ និងឆ្លើយសំណួរជាដៃគូ

ឧទាហរណ៍៖ What does Virak do at weekends?
He does housework.
- ឱ្យសិស្សធ្វើងផ្ទាត់ចម្លើយទាំងអស់

ចម្លើយ៖ 1. He gets up at half past six in the morning.
2. In the morning, he gets up, prepares his bedroom, brushes his teeth, washes his face, waters flowers, feeds chickens, has breakfast, cleans the house and washes his clothes.
3. After he has breakfast, he cleans the house and washes the clothes.
4. He cleans the house in the morning/after breakfast.

F. Speaking ការនិយាយ

Look at the pictures and practise with your partner.

ចូរមើលរូបភាព រួចអនុវត្តជាមួយដៃគូរបស់អ្នក

គ្រូ៖ - បង្ហាញរូបភាព ឱ្យសិស្សនិយាយពាក្យ wash clothes = បោកសម្លៀកបំពាក់, water flowers = ស្រោចផ្កា និង do exercise = ហាត់ប្រាណ

ឧទាហរណ៍៖ What time does she wash the clothes?

She washes the clothes at 6 o'clock.

- ឱ្យសិស្សបន្តសំណួរលើរូបភាពពីរផ្សេងទៀត

G. Writing សំណេរ

Fill the gaps with the correct words in your notebook.
ចូរបំពេញចន្លោះជាមួយពាក្យត្រឹមត្រូវក្នុងសៀវភៅសរសេររបស់អ្នក

គ្រូ៖ ពន្យល់សិស្សបានច្បាស់ពីរបៀបបំពេញពាក្យក្នុងចន្លោះ

ឧទាហរណ៍៖ I **brush** my teeth three times a day.

ចម្លើយ៖ I **wash** my face after I get up. My mother **cooks** food for my family. At weekends I **have** dinner with friends. I **chat** with my parents about my studies. Every Sunday I help my parents **clean**.

Remember ចូរចងចាំ

គ្រូ៖ - ប្រាប់សិស្សឱ្យចាំពាក្យ wash, eat, brush, clean និង cook

- ប្រាប់សិស្សពីរបៀបបង្កើតកាលដែលត្រូវប្រើជាមួយពេលវេលានៃថ្ងៃ

សំណួរ	ចម្លើយ
-***When*** **do** you stay at home?	-I ***stay*** at home in the ***afternoon.***
-***What*** **do** you do in the ***morning?***	-I ***wash*** my face, ***brush*** my teeth and ***clean*** the house.
-***What*** **does** she do in the ***evening?***	-She ***cooks, has*** dinner and ***studies.***

Unit 5: Time At School

មេរៀនទី៥៖ ពេលវេលានៅសាលារៀន

រយៈពេល ២ ម៉ោង

១. Objectives វត្ថុបំណង

- អានពាក្យ classroom, attendance list, library, sports និង board
- សរសេរ និងប្រកបពាក្យ classroom, attendance list, library, sports និង board
- បណ្តុះស្មារតីសិស្សឱ្យក្លាហានក្នុងការអនុវត្តសរសេរពាក្យ ការអានអត្ថបទខ្លីៗ ការសន្ទនា និងការបង្កើតសំណួរចម្លើយ

២. Teaching Materials សម្ភារៈបង្រៀន

- សៀវភៅសិក្សាគោល និងឯកសារជំនួយការបង្រៀនភាសាអង់គ្លេស
- រូបភាព និងបណ្ណពាក្យ classroom, attendance list, library, sports និង board
- អាត់សំឡេង CD, ម៉ាស៊ីនចាក់ DVD ឬ Smart Phone

៣. Teaching Process លំនាំបង្រៀន

A. Vocabulary រៀនពាក្យ

Look at the pictures. Listen and repeat.
ចូរមើលរូបភាព ស្តាប់ និងថាតាម

គ្រូ៖ - បង្ហាញរូបភាព និងសរសេរពាក្យនៅលើក្តារខៀន ហើយបិទរូបភាពនៅពីលើ ឬក្រោមពាក្យ classroom, attendance list, library, sportS និង board

- បកប្រែពាក្យជាភាសាខ្មែរ classroom = បន្ទប់រៀន, attendance list = បញ្ជីវត្តមាន, library = បណ្ណាល័យ, sports = កីឡា និង board = ក្តារខៀន

B. Spelling ការប្រកបពាក្យ

Spell each word in the box with your partner.
ចូរប្រកបពាក្យនីមួយៗក្នុងប្រអប់ជាមួយដៃគូរបស់អ្នក

គ្រូ៖ - ឱ្យសិស្សប្រកបពាក្យជាបុគ្គល ឬក្រុម

- ឱ្យសិស្សម្តងពីរនាក់ៗប្រកបពាក្យ

ឧទាហរណ៍៖ សិស្ស (A) និយាយថា Please spell the word ***board***
សិស្ស (B) ថា ***board*** I spell ***b-o-a-r-d*** រួចសរសេរនៅលើក្តារខៀន ហើយឱ្យសិស្សអានទាំងអស់គ្នា

- ឱ្យសិស្សអនុវត្តបន្តជាមួយពាក្យ classroom, attendance list, library និង sports

C. Conversation ការសន្ទនា

១. Listen to your teacher and repeat.
ចូរស្តាប់ និងថាតាមគ្រូរបស់អ្នក

គ្រូ៖ - អានសន្ទនាឱ្យសិស្សស្តាប់ និងថាតាមជាក្រុម

- ចែកសិស្សជាពីរក្រុមឱ្យសន្ទនាគ្នា
- ឱ្យសិស្សពីរនាក់សន្ទនាគ្នាជាគំរូ

២. Listen again and practise with your partner.
ចូរស្តាប់ម្តងទៀត រួចអនុវត្តជាមួយដៃគូរបស់អ្នក

គ្រូ៖ - អានសន្ទនាឱ្យសិស្សស្តាប់ម្តងទៀត រួចឱ្យសិស្សសន្ទនាតាមលំនាំ និងសកម្មភាពជាក់ស្តែង

D. Language Focus ការផ្តោតលើភាសា

Present Simple tense with ***'What'***.

បច្ចុប្បន្នកាលធម្មតាជាមួយ ***'What'***

គ្រូ៖ - ពន្យល់សិស្សពីការបង្កើតប្រយោគបច្ចុប្បន្នកាលធម្មតាជាមួយ ***'What'***

សំណួរ	ចម្លើយ
What do you do before class?	I clean the classroom.
What does your teacher do before the lesson starts?	She says "hello" to students and checks the attendance.

E. Reading អំណាន

១ . Listen to your teacher and repeat.

ចូរស្តាប់ និងថាតាមគ្រូរបស់អ្នក

គ្រូ៖ - ចម្លងអត្ថបទលើក្តារខៀន ឬបិទផ្ទាំងអត្ថបទ
- ឱ្យសិស្សទាំងអស់អានអត្ថបទស្ងាត់ និងប្រាប់នូវពាក្យពិបាក ឬពាក្យថ្មី
- អាន និងពន្យល់ពាក្យពិបាក
- ឱ្យសិស្សអានពាក្យ ឬអត្ថបទជាបុគ្គល ឬក្រុម
- ឱ្យសិស្សប្រកបពាក្យជាបុគ្គល ឬក្រុម
- ឱ្យសិស្សម្នាក់អានអត្ថបទ និងម្នាក់ទៀតបកប្រែជាភាសាខ្មែរ

២. Read the text again and answer the questions.

ចូរអានអត្ថបទម្តងទៀត រួចឆ្លើយសំណួរ

គ្រូ៖ - ឱ្យសិស្សម្នាក់អានអត្ថបទ និងម្នាក់ទៀតបកប្រែជាភាសាខ្មែរ
- ឱ្យសិស្សអានអត្ថបទស្ងាត់រៀងៗខ្លួន បន្ទាប់មកសួរ និងឆ្លើយសំណួរជាដៃគូ

ឧទាហរណ៍៖ Who is a good student?

Ratha is a good student.

- ឱ្យសិស្សធ្វើងផ្ទាត់ចម្លើយទាំងអស់

ចម្លើយ៖ 1. She joins the study club from three o'clock to half past four in the afternoon.
2. She sometimes helps her teacher work.
3. She goes to school early because she cleans the classroom and waters flowers.
4. Everyone at school knows her well because she works hard on all subjects and attends all school events.

F. Writing សំណេរ

Fill in the gaps with the correct word in your notebook.

ចូរបំពេញ ចន្លោះជាមួយពាក្យត្រឹមត្រូវដាក់ក្នុងសៀវភៅសរសេររបស់អ្នក

គ្រូ៖ ឱ្យសិស្សប្រើពាក្យក្នុងប្រអប់ដើម្បីបំពេញក្នុងចន្លោះឱ្យបានត្រឹមត្រូវ

ឧទាហរណ៍៖ I ***clean*** the classroom every Monday.

ចម្លើយ៖ 1. ***Study*** club helps me understand lessons.
2. When does your teacher check the ***attendance list***?

3. I play ***sports*** with friends every day.
4. I sometimes ***read*** books in the library at break time.
5. I have a snack at ***break*** time.

Remember ចូរចងចាំ

គ្រូ៖ - ប្រាប់សិស្សឱ្យចាំពាក្យ attendance list, classroom, sports, library និង board

- ប្រាប់សិស្សពីការបង្កើតប្រយោគបច្ចុប្បន្នកាលធម្មតាជាមួយ ***'What'***

សំណួរ	ចម្លើយ
What do you do before class?	I clean the classroom.
What does your teacher do before the lesson starts?	She says "hello" to students and checks the attendance.

Unit 6: Review

មេរៀនទី៦៖ រំឭកមេរៀនឡើងវិញ

រយៈពេល ១ ម៉ោង

១. Objectives វត្ថុបំណង

- រំឭករបៀបបង្កើតប្រយោគសំណួរ និងចម្លើយ
- រំឭកពាក្យដែលបានរៀនក្នុងជំពូកនេះ
- បណ្តុះស្មារតីសិស្សឱ្យក្លាហានក្នុងការអនុវត្តសរសេរពាក្យ ការអានអត្ថបទខ្លីៗ ការសន្ទនា និងការបង្កើតសំណួរចម្លើយ

២. Teaching Materials សម្ភារៈបង្រៀន

- សៀវភៅសិស្ស និងឯកសារជំនួយការបង្រៀនភាសាអង់គ្លេស
- រូបភាព និងបណ្តាពាក្យដែលត្រូវនឹងពាក្យក្នុងជំពូកនេះ
- ក្តារខៀន ក្តារឆ្នូន និងហ្វឺត ឬដីស
- អាត់សំឡេង CD, ម៉ាស៊ីនចាក់ DVD ឬ Smart Phone

៣. Teaching process លំនាំបង្រៀន

A. Language Focus ការផ្តោតលើភាសា

គ្រូ៖ ឱ្យសិស្សបង្កើតប្រយោគសំណួរ និងចម្លើយ បន្ទាប់មកឱ្យសិស្សអនុវត្តជាមួយដៃគូ ដោយម្នាក់សួរ និងម្នាក់ទៀតឆ្លើយ

B. Listening and Say ការស្តាប់ និងការនិយាយ

1. Say the word and point to the picture.
ចូរនិយាយពាក្យ និងចង្អុលរូបភាព

គ្រូ៖ - គ្រូបិទរូបភាពនៅលើក្តារខៀន បន្ទាប់មកឱ្យសិស្សម្នាក់ចង្អុលរូបភាព និងម្នាក់ទៀតនិយាយពាក្យ ឬឃ្លាឱ្យបានត្រឹមត្រូវ


ឧទាហរណ៍៖ សិស្សម្នាក់ចង្អុលរូប  និងម្នាក់ទៀតនិយាយថា watch TV

ចម្លើយ៖

 read a book

 brush teeth

 cook food

 wash clothes

 have a meal

 quarter to 7



quarter past 8



haft past 9



10 o'clock

C. Spelling ការប្រកបពាក្យ

Spell the words in the box with your partners.
ចូរប្រកបពាក្យនីមួយៗក្នុងប្រអប់ជាមួយដៃគូរបស់អ្នក

គ្រូ : - ឱ្យសិស្សម្តងពីរនាក់ៗប្រកបពាក្យ

ឧទាហរណ៍៖ សិស្ស (A) និយាយថា Please spell the word ***board*** ហើយសិស្ស (B) ថា ***board*** I spell ***b-o-a-r-d*** រួចសរសេរនៅលើក្តារខៀន ហើយឱ្យសិស្សអានទាំងអស់គ្នា

- ឱ្យសិស្សធ្វើរបៀបនេះរហូតអស់ពាក្យ

D. Writing សំណេរ

Write about your daily acitivities with clock times in your notebook.
ចូរសរសេរពីសកម្មភាពប្រចាំថ្ងៃរបស់អ្នកជាមួយពេលម៉ោងក្នុងសៀវភៅសរសេររបស់អ្នក

គ្រូ៖ ពន្យល់សិស្សបានច្បាស់ពីការសរសេរម៉ោងជាអក្សរ

ឧទាហរណ៍៖ 5:00 : **five o'clock**

ចម្លើយ៖

7:55 : five to eight
7:05 : five past seven
7:15 : quarter past seven
7:30 : half past seven
7:45 : quarter to eight
9:00 : nine o'clock
11:55 : five to twelve
12:05 : five past twelve
2:15 : quarter past two
4:30 : half past four

Chapter 2
ជំពូកទី២
THE DATE
កាលបរិច្ឆេទ

Unit 1: The Days
មេរៀនទី១៖ ថ្ងៃ
រយៈពេល ២ ម៉ោង

១. Objectives វត្ថុបំណង
- អានពាក្យ Sunday, Monday, Tuesday, Wednesday, Thursday, Friday និង Saturday
- សរសេរ និងប្រកបពាក្យ Sunday, Monday, Tuesday, Wednesday, Thursday, Friday និង Saturday
- បណ្តុះស្មារតីសិស្សឱ្យក្លាហានក្នុងការអនុវត្តសរសេរពាក្យ ការអានអត្ថបទខ្លីៗ ការសន្ទនា និងការបង្កើតសំណួរចម្លើយ

២. Teaching Materials សម្ភារៈបង្រៀន
- សៀវភៅសិស្ស និងឯកសារជំនួយការបង្រៀនភាសាអង់គ្លេស
- រូបភាព និងបណ្ណពាក្យ Sunday, Monday, Tuesday, Wednesday, Thursday, Friday និង Saturday
- ក្តារខៀន ក្តារឆ្នួន និងហ្វឺត ឬដីស
- អាត់សំឡេង CD, ម៉ាស៊ីនចាក់ DVD ឬ Smart Phone

៣. Teaching Process លំនាំបង្រៀន
A. Vocabulary រៀនពាក្យ
Look at the pictures. Listen and repeat.
ចូរមើលរូបភាព ស្តាប់ និងថាតាម

គ្រូ៖ - បង្ហាញបណ្ណពាក្យ ឬសរសេរពាក្យ Sunday, Monday, Tuesday, Wednesday, Thursday, Friday និង Saturday នៅលើក្តារខៀន រួចអានពាក្យម្តងមួយៗឱ្យសិស្សស្តាប់ បន្ទាប់មកឱ្យសិស្សថាតាម

- បកប្រែពាក្យជាភាសាខ្មែរ Sunday = ថ្ងៃអាទិត្យ, Monday = ថ្ងៃចន្ទ, Tuesday = ថ្ងៃអង្គារ, Wednesday = ថ្ងៃពុធ, Thursday = ថ្ងៃព្រហស្បតិ៍, Friday = ថ្ងៃសុក្រ និង Saturday = ថ្ងៃសៅរ៍

B. Spelling ការប្រកបពាក្យ
Spell each word in the box with your partners.

ចូរប្រកបពាក្យនីមួយៗក្នុងប្រអប់ជាមួយដៃគូរបស់អ្នក

គ្រូ៖ - ឱ្យសិស្សម្តងពីរនាក់ៗប្រកបពាក្យ

ឧទាហរណ៍៖ សិស្ស (A) និយាយថា please spell the word ***Monday.***

ហើយសិស្ស (B) ថា ***Monday*** I spell ***M-o-n-d-a-y.***

រួចសរសេរនៅលើក្តារខៀន បន្ទាប់ឱ្យសិស្សអានទាំងអស់គ្នា

- ឱ្យសិស្សអនុវត្តបន្តជាមួយពាក្យ Tuesday, Wednesday, Thursday, Friday, Saturday និង Sunday

C. Conversation ការសន្ទនា

១. Listen to your teacher and repeat.

ចូរស្តាប់ និងថាតាមគ្រូរបស់អ្នក

គ្រូ៖ - អានសន្ទនាឱ្យសិស្សស្តាប់ និងថាតាមជាក្រុម

- ចែកសិស្សជាពីរក្រុមឱ្យសន្ទនាគ្នា
- ឱ្យសិស្សពីរនាក់សន្ទនាគ្នាជាគំរូ

